CSEA
Center for Southeast Asians

### បាវចនារបស់ CSEA

បេសកកម្មរបស់CSEA គឺពង្រឹងភាពរុងរឿង, បេតិកភ័ណ្ឌ និងភាពជាអ្នកដឹកនាំនៃជនជាតិអាស៊ីអាគ្នេយ៍ក្នុងរដ្ឋRI។

### ចក្ខុវិស័យរបស់ CSEA

ជនជាតិអាស៊ីអាគ្នេយ៍គឺជាអ្នកចូលរួមដ៏សកម្មក្នុងសង្គម, រដ្ឋបាល និងជីវិតនយោបាយនៃរដ្ឋរ៉ូដអាយឡែន។ ជំនាន់របស់យើងធ្វើការរួមដៃគ្នាដើម្បីរក្សាប្រពៃណីនិងវប្បធ៌មរបស់ជនជាតិអាស៊ីអគ្នេយ៏, ត្រៀមសំរាប់អនាគត, សម្រេចបាននូវភាពរីកចំរើនខាងសេដ្ឋកិច្ចនិងទីបំផុត ធ្វើឲ្យសហគមន៍យើងរឹងមាំ។ មជ្ឈមណ្ឌលជនជាតិអាស៊ីអគ្នេយ៍ជាប្រភពស្វាគមន៍, រស់រវើក និងគួរជាទីទុកចិត្តសំរាប់ការវិវឌ្ឍន៍របស់សហគមន៍ជនជាតអាស៊ីអគ្នេយ៏។ យើងបណ្តុះបណ្តាលចំណេះវិជ្ជា និងជំនាញចាំបាច់ដើម្បីត្រៀមខ្លួនជាអ្នកដឹកនាំបច្ចុប្បន្ន និងទៅអនាគត។

### គោលការណ៍មគ្គុទេសក៍របស់ CSEA

- យើងសាមគ្គីនិងពួតដៃគ្នាដោយសារតែប្រវត្តិសាស្រ្តប្រពៃណីនិងវប្បធ៌មដ៏សំបូរបែបរបស់យើង។
- យើងប្តេជ្ញារកភាពជោគជ័យដល់អតិថិជនរបស់យើងជួយគាត់ឲ្យបោះជំហ៊ានទៅមុខ។ ដូច្នេះ យើងផ្តល់ចំណេះនិងជំនាញចំបាច់ដល់អតិថិជនរបស់យើងដើម្បីឲ្យពួកគាត់អាចម្ចាស់ការនិងឧបត្ថម្ភខ្លួនឯងបាន។
- យើងកាន់ខ្ជាប់នូវស្តង់ដាខ្ពស់បំផុតសំរាប់ការអនុវត្តន៍និងភាពសុចរិក។
- យើងមានការទទួលខុសត្រូវចំពោះសហគមន៍របស់យើងដើម្បីផលិតផលល្អ។
- យើងផ្តល់តម្លៃភាពសហការ និងកសាងភាពជាដៃគូដើម្បីជំរុញកម្មវិធីនិងសេវាកម្មរបស់យើង។

## សុវត្ថិភាពខ្សែក្រវ៉ាត់និរភ័យ

- គ្រោះថ្នាក់រថយន្តគឺជាមូលហេតុនាំមុខគេនៃការស្លាប់ក្នុងចំណោមមនុស្សអាយុ ៥-៣៤ឆ្នាំ ក្នុងស.រ.អ (CDC)។
- អ្នកបើកបរនិងអ្នកដំណើរពេញវ័យចំនួនជាង ២.៣លាននាក់ត្រូវគេព្យាបាលក្នុងមន្ទីរសង្គ្រោះបន្ទាន់ដោយសារតែរបួសក្នុងរថយន្តដែលគ្រោះថ្នាក់ក្នុងឆ្នាំ ២០០៩ (CDC)។
- រៀងរ៉ាល់ ១២នាទី: មានមនុស្សម្នាក់ស្លាប់ក្នុងគ្រោះថ្នាក់រថយន្តនៅក្នុងស.រ.អ។ រៀងរ៉ាល់ ១០វិនាទី: មានមនុស្សម្នាក់រងរបួសក្នុងគ្រោះថ្នាក់រថយន្តនៅក្នុងស.រ.អ(CDC)។
- ៥៣%នៃអ្នកបើកបរនិងអ្នកដំណើរដែលបានស្លាប់ក្នុងគ្រោះថ្នាក់រថយន្តក្នុងឆ្នាំ ២០០៩ មិនបានពាក់ខ្សែក្រវាត់និរភ័យ។ (DOT, NHTSA)
- អ្នកដែលមិនពាក់ខ្សែក្រវ៉ាត់និរភ័យត្រូវខ្ទាតចេញ៣០ដងពីរថយន្តក្នុងពេលមានគ្រោះថ្នាក់ និងឱកាស៧៥%ក្នុងការស្លាប់។ (DOT, NHTSA)
- ក្នុងចំណោមអ្នកបើកនិងអ្នកដំណើរអង្គុយកៅអីមុខ ខ្សែក្រវ៉ាត់និរភ័យកាត់បន្ថយភាពគ្រោះថ្នាក់បាត់បង់ជីវិតដល់ទៅ៤៥% ហើយកាត់បន្ថយភាពគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ទៅ៥០%។ (DOT, NHTSA)
- ពីឆ្នាំ២០០៤ ទៅ២០០៨ ខ្សែក្រវ៉ាត់និរភ័យសង្គ្រោះជីវិត៧៥,០០០នាក់-ចំនួនមនុស្សគ្រប់គ្រាន់ដែលអាចបំពេញពហុកីឡាដ្ឋានដ៏ធំមួយបាន។(NHTSA)

## ច្បាប់ខ្សែក្រវ៉ាត់និរភ័យបឋម

- អ្នកបើកបរ**និង**អ្នកដំណើរត្រូវតែពាក់ខ្សែក្រវ៉ាត់និរភ័យគ្រប់ពេលវេលាទាំងអស់។ (RI DOT)
- អាយុ៧ឆ្នាំ ចុះ = ពិន័យ$៨៥ សំរាប់បទល្មើសនិមួយៗ (RI DOT)
- អាយុ៨ឆ្នាំ ឡើង = ពិន័យ$៤០ សំរាប់បទល្មើសនិមួយៗ (RI DOT)
- អ្នកបើកបរត្រូវទទួលខុសត្រូវចំពោះបទល្មើសទាំងអស់ (RI DOT)
- ប៉ូលីសត្រូវតែមានការសង្ស័យសមហេតុផលថា អ្នកបើកបរឬក៏អ្នកជិះរថយន្តមិនពាក់ខ្សែក្រវ៉ាត់ (RI DOT)
- ប៉ូលីស**មិនអាច**ឆែកឆេររថយន្ត, អ្នកបើកបរ ឬក៏អ្នកជិះ ដោយសារតែអ្នកបើកបរ ឬក៏អ្នកជិះនោះមិនបានពាក់ខ្សែក្រវ៉ាត់ឡើយ (RI DOT)

**សហការជាមួយ:**

ក្រសួងដឹកជញ្ជូនរដ្ឋ RI

HOPE
Hope, Unity and Action
ដៃគូសហគមន៍ក្រុមស្បែកខ្មៅនិងឡាទីណូ


**ការិយាល័យធំ** 270 Elmwood Avenue, Providence, RI 02907, ទូរស័ព 401-274-8811Þ

**ការិយាល័យសាខា** 727 Front Street, Suite 110, Woonsocket, RI 02985, ទូរស័ព្ទ 401-762-0343